ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខ័ណ្ឌកម្មវិធីសិក្សា

## បរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈ
## នាយកសាលាមធ្យមសិក្សាទុតិយភូមិ

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២០

# មុខកថា

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យប្រែក្លាយកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ កម្ពុជាចាំបាច់ត្រូវមានធនធានមនុស្សដែលមានគុណតម្លៃសតវត្សទី២១ ដូចជាការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា គំនិតច្នៃប្រឌិតនិងនវានុវត្តន៍ និងស្មារតីស្នេហាជាតិ ប្រកបដោយចំណេះដឹង ជំនាញ ឥរិយាបថ សុខភាពល្អ និងមានភាពជាពលរដ្ឋសាកល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៩-២០២៣) និងក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (២០១៦-២០៣០)។

ឆ្លើយតបទៅនឹងចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ២០១៨-២០២៣ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដោយឈរលើគោលការណ៍គុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ដើម្បីពង្រឹងគុណភាពសិស្ស និងការគ្រប់គ្រងតាមសាលារៀន តាមរយៈការពង្រឹងគុណវុឌ្ឍិគ្រូ គណៈគ្រប់គ្រងសាលារៀន និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ។

ក្របខណ្ឌកម្មវិធីសិក្សា បរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ត្រូវបានរៀបចំឡើង ដើម្បីផ្ដល់ជូនបុគ្គលិកអប់រំ ដែលមានសក្ដានុពល ក្នុងការក្លាយខ្លួនទៅជាគណៈគ្រប់គ្រងសាលារៀន ឬនាយកសាលារៀន ឱ្យមានសមត្ថភាពវិជ្ជាជីវៈ មនសិការ ការដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីផ្ដល់ការគាំទ្រដល់គ្រូបង្រៀន និងអ្នកសិក្សា ឱ្យទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការអប់រំប្រកបដោយគុណភាព។

ក្រសួងអប់រំ យុវជន និងកីឡា សូមសម្ដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះមន្ត្រីអប់រំនៃវិទ្យាស្ថានជាតិអប់រំ និងអ្នកពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងជម្នះរាល់ការលំបាក និងបានចូលរួមចំណែកយ៉ាងពេញលេញ ក្នុងការអភិវឌ្ឍក្របខ័ណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនេះឡើង ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសង្គម និងការវិវត្តជាសាកល។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះ នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីបណ្ដុះបណ្ដាលគណៈគ្រប់គ្រងសាលា ឬនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅទូទាំងប្រទេស សម្រាប់ការរួមចំណែកអភិវឌ្ឍធនធានមនុស្ស និងសង្គមប្រកបដោយចីរភាព។

ថ្ងៃ ពុធ ៣ កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

# គណៈកម្មការ

## I. គណៈកម្មការគ្រប់គ្រង

| | | | |
|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម | លាង សេងហាក់ | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤. ឯកឧត្តម | ងួន មាស | អគ្គនាយកនៃអគ្គ.រដ្ឋបាល&ហិរញ្ញវត្ថុ | សមាជិក |
| ៥. លោកបណ្ឌិត | ឌី សមស៊ីដេត | អគ្គនាយករងនៃអគ្គនា.ដ្ឋានអប់រំ | សមាជិក |
| ៦. ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | អគ្គនាយករងនៃអគ្គ.អគផ | សមាជិក |
| ៧. លោកជំទាវបណ្ឌិត | ឃួន វិច្ឆិកា | អគ្គនាយករងនៃអគ្គនា.ដ្ឋានអប់រំ | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩. លោក | ង៉ោ ប៉េងឡុង | ប្រធាននា.ប.ប និងវិក្រឹតការ | សមាជិក |
| ១០. លោក | ណែប ស៊ីនថៃ | អ្នកសម្របសម្រួលគម្រោង | សមាជិក |

## II. ក្រុមការងារបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលក្រោយឧត្តម និងការបណ្តុះបណ្តាលបន្ត

| | | | |
|---|---|---|---|
| ១. លោកបណ្ឌិត | នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២. លោកបណ្ឌិត | សុខ សូត្រ | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃស.ភ.ភ.ព | អនុប្រធាន |
| ៣. លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | អនុប្រធាននា.បណ្តុះបណ្តាលនិងវិក្រឹតការ | អនុប្រធាន |
| ៤. លោក | យិន ស៊ីដា | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៥. លោកបណ្ឌិត | អ៊ែ ស៊ុនហ៊ាង | នាយកមជ្ឈ.តំបន់អាស៊ីអាគ្នេយ៍.បច្ចេកទេស | សមាជិក |
| ៦. លោក | មាក សុភា | ប្រ.ការិយាល័យនៃនា.ធានាគុណភាពអប់រំ | សមាជិក |
| ៧. លោក | ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ | សមាជិក |
| ៨. លោក | ចាប រតនា | អនុប្រ.ដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ | សមាជិក |
| ៩. លោកបណ្ឌិត | ឈាង សង្វាត | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០. លោកបណ្ឌិត | ម៉ម សុជាតិ | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១១. លោកបណ្ឌិត | សុត វិសាល | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១២. លោកស្រីបណ្ឌិត | ស្វាយ សោមា | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១៣. កញ្ញា | ហ៊ ស៊ីរី | ប្រធានការិ.នៃវិ.បច្ចេកវិទ្យាកំពង់ស្ពឺ និងជាសមាជិក លេខាធិការដ្ឋានអភិវឌ្ឍ.គរុកោសល្យ | សមាជិក |
| ១៤. លោក | ម៉ែន សំណាង | មន្ត្រីលេខាធិការដ្ឋាននៃអគ្គ.អប់រំ និងជាសមាជិក លេខាធិការដ្ឋានអភិវឌ្ឍ.គរុកោសល្យ | សមាជិក |

# មាតិកា

ទំព័រ

បុព្វកថា ........ i
គណៈកម្មការ ........ ii
មាតិកា ........ iii
១. សេចក្តីផ្តើម ........ 1
២. ចក្ខុវិស័យ ........ 2
៣. បេសកកម្ម ........ 2
៤. គោលបំណង ........ 2
៥. វិសាលភាព ........ 2
៦. រយៈពេល និងកាលវិភាគសិក្សា ........ 3
៧. ការកំណត់ក្រេឌីតសិក្សា ........ 3
៨. ប្រព័ន្ធចំណាត់ថ្នាក់ពិន្ទុ (GPA) ........ 3
៩. ការសរសេរនិក្ខេបបទ ការធ្វើសិក្ខាសាលា បាឋកថា និងសកម្មភាពផ្សេងៗ ........ 4
១០. សុចរិតភាពនៃការសិក្សា ........ 4
១១. រចនាសម្ព័ន្ធនៃក្របខ័ណ្ឌកម្មវិធីសិក្សា ........ 5
១២. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា ........ 7
១៣. ការវាយតម្លៃការបណ្តុះបណ្តាល ........ 10
ឯកសារយោង ........ 11

## ១. សេចក្តីផ្តើម

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដោយឈរលើគោលនយោបាយអប់រំចំនួនពីរ ដែលក្នុងនោះគោលនយោបាយមួយបានលើកឡើងពីការធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់។

ក្រសួង ក៏បានដាក់ចេញនូវវិធានការអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដែលរួមមាន៨ចំណុច នៅឆ្នាំ២០១៣ និង១៥ចំណុចនៅឆ្នាំ២០១៤ ដោយឈរលើសរសរស្តម្ភ៥ ក្នុងនោះ សរសរស្តម្ភទី១ បានកំណត់ឱ្យអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលផ្តោតសំខាន់លើការបង្កើនគុណវុឌ្ឍិ និងបទពិសោធបុគ្គលិកអប់រំ ការអភិវឌ្ឍវិជ្ជាជីវៈ ការរៀបចំគន្លងអាជីពគ្រូបង្រៀន និងការពង្រឹងអភិបាលកិច្ចតាមគ្រឹះស្ថានសិក្សា តាមរយៈរៀបចំស្តង់ដា និងបណ្តុះបណ្តាលនាយកសាលារៀនផ្អែកតាមយុទ្ធសាស្រ្តទី៨នៃគោលនយោបាយស្តីពីគ្រូបង្រៀន គឺការពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន។ ជាមួយគ្នានេះ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ ស្តីពីគុណភាពអប់រំ បានកំណត់ចំណុចដៅថា យ៉ាងយូរឆ្នាំ២០៣០ នឹងបង្កើនឱ្យបាននូវការបញ្ជូនគ្រូដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឱ្យទៅគ្រប់សាលារៀនទាំងអស់។ ផ្អែកតាមគោលដៅនេះ នាយកសាលារៀន ក៏ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាព ភាពច្នៃប្រឌិតខ្ពស់ និងការប្រាស្រ័យទាក់ទងល្អ សម្រាប់ផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតប។

ក្របខ័ណ្ឌសមត្ថភាពនាយកសាលាអាស៊ានបានកំណត់ថា នាយកសាលាគឺជាអ្នកបញ្ជាក្នុងដំណើរការប្រចាំថ្ងៃរបស់សាលារៀន និងចាំបាច់ត្រូវមានក្របខ័ណ្ឌសមត្ថភាពចំនួន៥គឺៈ (១) ជាបុគ្គលិកឆ្នើម ឬជាបុគ្គលប្រកបដោយឧត្តមភាព (Personal Excellence) (២) ជាគ្រូឧទ្ទេសឆ្នើម អ្នកចង្អុលបង្ហាញដ៏ល្អ ឬជាអ្នកគ្រប់គ្រងលើការបង្រៀននិងរៀន (Instructional Leadership) (៣) ជាអ្នកគ្រប់គ្រងឆ្នើម ឬអ្នកដឹកនាំឆ្នើម (Managerial Leadership) (៤) ជាអ្នកមានគំនិតជាយុទ្ធសាស្រ្តច្នៃប្រឌិត និងនវានុវត្តន៍ (Strategic Thinking and Innovation) និង (៥) ជាអ្នកមានទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ (Stakeholder Engagement)។

គុណភាពអប់រំគឺជាគុណភាពគ្រូបង្រៀន និងគុណភាពនាយកសាលារៀន។ ក្នុងន័យនេះ កំណែទម្រង់វិស័យអប់រំនាពេលបច្ចុប្បន្នផ្តោតទៅលើការពង្រឹងការគ្រប់គ្រងសាលារៀន ការពង្រឹងគុណភាពគ្រូ និងការកែលម្អការបង្រៀននិងរៀន ដោយផ្តល់ឱ្យសាលារៀននូវស្វ័យភាពហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ នាយកសាលាមានសិទ្ធិទទួល ឬបដិសេធ និងបញ្ឈប់បុគ្គលិកតាមកិច្ចសន្យា និងមានសិទ្ធិលើកសំណើរ លើកទឹកចិត្តដល់បុគ្គលិកជាប្រចាំ មានប្រាក់ឧបត្ថម្ភទៅតាមទំហំការងារ មានការលើកទឹកចិត្តដោយគិតពីអតីតភាពការងារជានាយក និងលទ្ធផលការងារ៥ឆ្នាំឡើងស័ក្តិម្តង និងផ្តល់ឯកសណ្ឋានតាមឋានៈ។

ឆ្លើយតបទៅនឹងការរីកចម្រើន និងបញ្ហាខាងលើ ក្រសួងបានកំណត់ស្តង់ដានាយកសាលារៀន

ដែលផ្តោតជាសំខាន់លើគុណវុឌ្ឍិនិងបទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រនិងនវានុវត្តន៍ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងការរៀនតាមបរិបទថ្មីក្នុងសតវត្សទី២១ ឧត្តមភាពរបស់នាយកសាលារៀន និងការផ្សារភ្ជាប់សាលារៀននឹងសហគមន៍ ព្រមទាំងបង្កឱ្យមានលទ្ធភាពអភិវឌ្ឍខ្លួនពេញមួយជីវិត និងមានលទ្ធភាពដោះស្រាយបញ្ហាប្រឈមថ្មីៗ ក្នុងគោលដៅពង្រឹងការផ្តល់សេវាអប់រំប្រកបដោយគុណភាព ភាពឆ្លើយតប និងសុខដុមនីយកម្មក្នុងអង្គភាព។

## ២. ចក្ខុវិស័យ

គណៈគ្រប់គ្រងឬនាយកសាលារៀនប្រកបដោយសមត្ថភាព មនសិការវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ ដែលផ្តល់ការគាំទ្រដល់គ្រូបង្រៀនឱ្យទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងអ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយ គុណភាព សមធម៌ និងបរិយាបន្ន រួមចំណែកដល់ការអភិវឌ្ឍសង្គមពុទ្ធិប្រកបដោយចីរភាព។

## ៣. បេសកកម្ម

ផ្តល់នូវចំណេះដឹង និងជំនាញច្បាស់លាស់លើការគ្រប់គ្រង និងការដឹកនាំសាលារៀន ប្រកបដោយប្រសិទ្ធភាព។

## ៤. គោលបំណង

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈដល់គណៈគ្រប់គ្រង ឬនាយកសាលាមធ្យមសិក្សាទុតិយភូមិស្របតាមស្តង់ដាតំបន់ និងអន្តរជាតិ
- តម្រង់ទិសដល់ការដឹកនាំ និងការគ្រប់គ្រង ឆ្ពោះទៅបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដែលធានាបាននូវលទ្ធផលសិក្សាល្អសម្រាប់សិស្សានុសិស្ស។

## ៥. វិសាលភាព

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ មានវិសាលភាពអនុវត្តចំពោះ គណៈគ្រប់គ្រងសាលារៀន ដែលរួមមាននាយក នាយិកា នាយករង និងនាយិការង ក្នុងក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡា។

## ៦. រយៈពេល និងកាលវិភាគសិក្សា

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ មានរយៈពេល០១ឆ្នាំ និងត្រូវចែកចេញជា០២ផ្នែកធំៗគឺ ការសិក្សាស្រាវជ្រាវក្នុងថ្នាក់មានរយៈពេល០៦ខែ និងការចុះធ្វើកម្មសិក្សាស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទមានរយៈពេល០៦ខែ។ រីឯកាលវិភាគសិក្សាវិញ ក៏ត្រូវបានបែងចែកជា០២ប្រភេទ សម្រាប់អ្នកសិក្សាជ្រើសរើសដែរ គឺការសិក្សាក្នុងសប្ដាហ៍ (ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ) និងការសិក្សាចុងសប្ដាហ៍ (ពីថ្ងៃសៅរ៍ ដល់ថ្ងៃអាទិត្យ)។

## ៧. ការកំណត់ក្រេឌីតសិក្សា

ក្របខ័ណ្ឌនៃកម្មវិធីសិក្សានេះ មានចំនួន៤៨ក្រេឌីត និងតម្រូវឱ្យអ្នកសិក្សាចំណាយពេល ០១ឆ្នាំ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ។ ក្នុងរយៈពេល០១ឆ្នាំនេះ អ្នកសិក្សាត្រូវធ្វើការសិក្សា និងស្រាវជ្រាវលើមុខវិជ្ជាចំនួន ០៨ ដែលចែកជាម៉ូឌុលសរុបចំនួន២១ ស្មើនឹង៤២ក្រេឌីត និងការសរសេរនិក្ខេបបទដែលមានចំនួន០៦ក្រេឌីត។ ដើម្បីទទួលបាន០១ក្រេឌីត អ្នកសិក្សាត្រូវចំណាយពេល១៥ម៉ោង ដោយសិក្សាផ្ទាល់ជាមួយសាស្ត្រាចារ្យក្នុងថ្នាក់ ឬ៣០ម៉ោង ដោយអនុវត្តក្នុងមន្ទីរពិសោធន៍ ឬ៤៥ម៉ោង ដោយធ្វើស្វ័យសិក្សាខ្លួនឯង។

## ៨. ប្រព័ន្ធចំណាត់ថ្នាក់ពិន្ទុ (GPA)

អ្នកសិក្សាទាំងអស់ ត្រូវធ្វើការប្រឡងលើគ្រប់មុខវិជ្ជាដែលបានរៀបចំដោយផ្ទាល់ពីសាស្ត្រាចារ្យដែលបង្រៀនមុខវិជ្ជាទាំងនោះ។ វិទ្យាស្ថានជាតិអប់រំ ធ្វើការកំណត់ថាសម្រាប់អ្នកប្រឡងជាប់ ត្រូវមានមធ្យមភាគពិន្ទុនិទ្ទេសចាប់ពី២.៥០ ឡើងទៅ (ក្នុងប្រព័ន្ធ ៤.០០) ឬ និទ្ទេស C+ ទើបអាចផ្ដល់ជូន ឬបញ្ជាក់ជូនសញ្ញាបត្របាន។ ខាងក្រោមនេះ គឺជាប្រព័ន្ធដាក់ពិន្ទុ និងការផ្ដល់និទ្ទេស។

$$GPA = \frac{\sum(P \,.\, C)}{\sum C}$$

រូបមន្តក្នុងការគណនារកមធ្យមពិន្ទុនិទ្ទេសគឺ មធ្យមភាគពិន្ទុនិទ្ទេស ស្មើនឹងផលបូកនៃផលគុណរវាងពិន្ទុនិទ្ទេស (P) គុណនឹងតម្លៃក្រេឌីត (C) ចែកនឹងផលបូកនៃចំនួនក្រេឌីតគ្រប់មុខវិជ្ជា។

| សមាសភាគភាគរយ ឬថ្នាក់ពិន្ទុ | ពិន្ទុតាមកម្រិត ឬពិន្ទុនិទ្ទេស | សញ្ញាពិន្ទុជាអក្សរ ឬ ថ្នាក់និទ្ទេស | ការបរិយាយ |
|---|---|---|---|
| ៨៥-១០០ | ៤.០០ | A | ល្អប្រសើរ |
| ៨០-៨៤ | ៣.៥០ | B+ | ល្អណាស់ |
| ៧០-៧៩ | ៣.០០ | B | ល្អ |
| ៦៥-៦៩ | ២.៥០ | C+ | ល្អបង្គួរ |
| ៥០-៦៤ | **២.០០** | C | មធ្យម |
| ៤៥-៤៩ | ១.៥០ | D | ខ្សោយ |
| ៤០-៤៤ | ១.០០ | E | ខ្សោយណាស់ |
| ០-៣៩ | ០.០០ | F | ធ្លាក់ |

## ៩. ការសរសេរនិក្ខេបបទ ការធ្វើសិក្ខាសាលា បាឋកថា និងសកម្មភាពផ្សេងៗ

### ៩.១. ការសរសេរនិក្ខេបបទ

អ្នកសិក្សា តម្រូវឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទ បំពេញលក្ខខណ្ឌនៃការសិក្សា និង តម្រូវឱ្យធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវតាមដំណាក់កាលដែលកំណត់ក្នុងផែនការបណ្ដុះបណ្ដាល។ និក្ខេបបទ ត្រូវមានចំនួនកំណត់យ៉ាងតិច ៦០ទំព័រ ដោយមិនគិតពីឧបសម្ព័ន្ធ និងឯកសារយោង។

### ៩.២. សិក្ខាសាលាឬបាឋកថា

អ្នកសិក្សា តម្រូវឱ្យចូលរួមសិក្ខាសាលា ឬបាឋកថាកម្រិតគ្រឹះស្ថានសិក្សា កម្រិតជាតិ ឬអន្តរជាតិ យ៉ាងតិច០១ដងក្នុងវគ្គសិក្សា។

## ១០. សុចរិតភាពនៃការសិក្សា

អ្នកសិក្សា ត្រូវបង្ហាញនូវសុចរិតភាពនៃការសិក្សារបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀន រហូតដល់ចុងបញ្ចប់នៃការសិក្សា។ ក្នុងន័យនេះ អ្នកសិក្សា មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗ របស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនឡើយ បើគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឬឯកសារពិគ្រោះ។ បើពុំនោះទេ នឹងត្រូវប្រឈមនឹងការទទួលពិន័យ ការដាក់ឱ្យរៀនត្រួតថ្នាក់ ឬរៀនមុខវិជ្ជានោះឡើងវិញ ឬបើធ្ងន់ធ្ងរជាងនេះ នឹងត្រូវលប់ឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិត។

## ១១. រចនាសម្ព័ន្ធនៃក្របខ័ណ្ឌកម្មវិធីសិក្សា

### ១១.១. លក្ខណៈសម្បត្តិដើម្បីទទួលសញ្ញាបត្រ

ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ មានចំនួន៤៨ក្រេឌីត និងចែកចេញជា៖

(១) មុខវិជ្ជាសិក្សាចំនួន០៨មុខវិជ្ជា ស្មើ៤២ក្រេឌីត។ មុខវិជ្ជាទាំង០៨ នេះ ត្រូវបានបង្រៀន ក្នុងគោលបំណង ផ្តល់ចំណេះដឹង ជំនាញ និងឥរិយាបទសំខាន់ៗ ក្នុងការប្រតិបត្តិអាជីព ជានាយកសាលា។

(២) ការសរសេរនិក្ខេបបទ បន្ទាប់ពីបញ្ចប់មុខវិជ្ជាសិក្សាទាំង០៨ ខាងលើ។ និស្សិតទាំងអស់ តម្រូវឱ្យធ្វើគម្រោងស្រាវជ្រាវ ធ្វើកម្មសិក្សាប្រតិបត្តិ និងសរសេរនិក្ខេបបទ ក្នុងគោលបំណងផ្តល់ឱកាសដល់អ្នកសិក្សា ដើម្បីសិក្សា និងដកស្រង់បទពិសោធពីការគ្រប់គ្រងសាលារៀនរៀងៗខ្លួន និងនិក្ខេបបទ ដែលមាន០៦ក្រេឌីត ដោយតម្រូវឱ្យធ្វើការពារនិក្ខេបបទសម្រាប់បំពេញលក្ខខណ្ឌនៃការសិក្សា។

### ១១.២. មុខវិជ្ជាសិក្សា

| ល.រ | ចំណងជើងមុខវិជ្ជា និងម៉ូឌុល | ម៉ោង | ក្រេឌីត |
|---|---|---|---|
| ១ | **គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍** | | |
| | មុខវិជ្ជាទី១.១៖ ទស្សនៈវិទ្យានៃការអប់រំ ច្បាប់ និងគោលនយោបាយអប់រំ | ៣០ | ២ (២-០-៦) |
| | មុខវិជ្ជាទី១.២៖ ផែនការ និងយុទ្ធសាស្ត្រក្នុងវិស័យអប់រំ | ៤៥ | ៣ (៣-០-៩) |
| | មុខវិជ្ជាទី១.៣៖ ការលើកទឹកចិត្ត៖សិល្បៈនៃការដឹកនាំនិងគ្រប់គ្រងសាលារៀន | ៣០ | ២ (២-០-៦) |
| ២ | **ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (១)៖ ការគ្រប់គ្រងធនធាន** | | |
| | មុខវិជ្ជាទី២.១៖ ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក | ៣០ | ២ (២-០-៦) |
| | មុខវិជ្ជាទី២.២៖ ការគ្រប់គ្រងធនធានសម្ភារៈ និងហិរញ្ញវត្ថុ | ៣០ | ២ (២-០-៦) |
| | មុខវិជ្ជាទី២.៣៖ ការគ្រប់គ្រងគម្រោង និងកម្មវិធីរបស់សាលារៀន | ៣០ | ២ (២-០-៦) |
| ៣ | **ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (២)៖ ការលើកកម្ពស់ការបង្រៀន និងរៀន** | | |
| | មុខវិជ្ជាទី៣.១៖ ការដឹកនាំការអនុវត្ត និងកែលម្អកម្មវិធីសិក្សា | ៣០ | ២ (២-០-៦) |
| | មុខវិជ្ជាទី៣.២៖ ការបង្កើតបរិស្ថានសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល | ៣០ | ២ (២-០-៦) |
| | មុខវិជ្ជាទី៣.៣៖ ការពិនិត្យកែលម្អ និងវាយតម្លៃការបំពេញការងាររបស់គ្រូ | ៣០ | ២ (២-០-៦) |
| ៤ | **ឧត្តមភាពបុគ្គល** | | |

| | | | |
|---|---|---|---|
| | មុខវិជ្ជាទី៤.១៖ ការគ្រប់គ្រងប្រសិទ្ធភាពបុគ្គល | ១៥ | ១ (១-០-៣) |
| | មុខវិជ្ជាទី៤.២៖ ស្តង់ដានាយកសាលារៀន | ១៥ | ១ (១-០-៣) |
| | មុខវិជ្ជាទី៤.៣៖ ស្តង់ដាគ្រូបង្រៀន | ១៥ | ១ (១-០-៣) |
| | មុខវិជ្ជាទី៤.៤៖ ក្រមសីលធម៌វិជ្ជាជីវៈរបស់នាយកសាលា | ៣០ | ២ (២-០-៦) |
| **៥** | **ការចូលរួមរបស់ភាគីពាក់ព័ន្ធ** | | |
| | មុខវិជ្ជាទី៥.១៖ ការលើកកម្ពស់ភាពទទួលខុសត្រូវចំពោះសាលារៀន | ១៥ | ១ (១-០-៣) |
| | មុខវិជ្ជាទី៥.២៖ ការគ្រប់គ្រងបណ្តាញ និងសម្ព័ន្ធភាពអប់រំ | ១៥ | ១ (១-០-៣) |
| | មុខវិជ្ជាទី៥.៣៖ ការរក្សានិរន្តរភាពទំនាក់ទំនង និងសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ | ១៥ | ១ (១-០-៣) |
| **៦** | **អធិការកិច្ចសាលារៀន** | | |
| | មុខវិជ្ជាទី៦.១៖ ប្រព័ន្ធអធិការកិច្ច និងការវាយតម្លៃ | ៤៥ | ៣ (៣-០-៩) |
| | មុខវិជ្ជាទី៦.២៖ ស្វ័យវាយតម្លៃសាលារៀន | ៤៥ | ៣ (៣-០-៩) |
| **៧** | **ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ** | | |
| | មុខវិជ្ជាទី៧.១៖ បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យអប់រំ | ៤៥ | ៣ (៣-០-៩) |
| | មុខវិជ្ជាទី៧.២៖ ភាសាបរទេសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈនិងការស្រាវជ្រាវ | ៤៥ | ៣ (៣-០-៩) |
| **៨** | **វិធីសាស្ត្រនៃការស្រាវជ្រាវក្នុងវិស័យអប់រំ** | | |
| | មុខវិជ្ជាទី៨.១៖ ការសិក្សាស្រាវជ្រាវប្រតិបត្តក្នុងការរៀននិងបង្រៀន | ៤៥ | ៣ (៣-០-៩) |
| **ក្រេឌីតសម្រាប់ការរៀនតាមមុខវិជ្ជា និងតាមម៉ូឌុលនៅក្នុងថ្នាក់** | | **៦៣០** | **៤២** |
| **ការពារគម្រោងស្រាវជ្រាវ កម្មសិក្សាប្រតិបត្តិនិងសរសេរនិក្ខេបបទ** | | **៩០** | **៦** |
| **សរុប** | | **៧២០** | **៤៨** |

## ១១.៣. ការកំណត់ និងការវាយតម្លៃ ដើម្បីផ្ទេរក្រេឌីតសិក្សា

- អ្នកសិក្សា អាចផ្ទេរចំនួនក្រេឌីតដែលបានសិក្សាលើមុខវិជ្ជាដូចក្នុងកម្មវិធីសិក្សាខាងលើ ដើម្បីទទួលវិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន។
- អ្នកសិក្សា ដែលបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលមានមុខវិជ្ជាសមមូលទៅនឹងមុខវិជ្ជាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំផ្ទេរក្រេឌីតបាន។
- ការផ្ទេរក្រេឌីត អាចផ្តល់ឱ្យអ្នកសិក្សាណាដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ ហើយអាច

ផ្ទេរបានច្រើនបំផុតត្រឹមតែ០៩ក្រេឌីត។

- អ្នកសិក្សា ត្រូវតែដាក់ច្បាប់ចម្លងនៃកម្មវិធីសិក្សាសង្ខេប ដោយភ្ជាប់ជាមួយនូវព្រឹត្តិបត្រពិន្ទុសម្រាប់មុខវិជ្ជាណាដែលបានសុំផ្ទេរក្រេឌីត។

## ១២. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា

### មុខវិជ្ជាទី១៖ គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍ (០៧ក្រេឌីត)

មុខវិជ្ជានេះ ផ្តល់នូវយុទ្ធសាស្ត្រក្នុងការធ្វើផែនការអភិវឌ្ឍន៍សាលារៀនប្រកបដោយប្រសិទ្ធភាព ដោយមានការចូលរួមកសាង និងអនុវត្តផែនការពីអ្នកពាក់ព័ន្ធនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមក្នុងសាលា ក៏ដូចជាក្នុងវិស័យអប់រំទាំងមូល ស្របតាមនិន្នាការប្រទេសជាតិ តំបន់ និងពិភពលោកដែលកំពុងមានការវិវត្តរីកចម្រើនគួរកត់សម្គាល់។ មុខវិជ្ជានេះ នឹងផ្តល់ដល់សិក្ខាកាមឱ្យចេះធ្វើផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការអប់រំនានាដែលទាក់ទង។

### មុខវិជ្ជាទី២៖ ការគ្រប់គ្រងសាលារៀន (១)៖ ការគ្រប់គ្រងធនធាន (០៦ក្រេឌីត)

មុខវិជ្ជានេះ ផ្តល់នូវចំណេះដឹង និងជំនាញដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានទាំងអស់របស់សាលារៀន ដូចជាការគ្រប់គ្រងធនធានសម្ភារ ថវិកា ការចាត់ចែង និងការគ្រប់គ្រងបុគ្គលិកជាដើម។ ចំពោះការគ្រប់គ្រងបុគ្គលិក អ្នកសិក្សានឹងទទួលបាននូវជំនាញគ្រឹះក្នុងការគ្រប់គ្រងធនធានមនុស្ស ការវាយតម្លៃការងារ និងការគ្រប់គ្រងសាលារៀនរួមមាន៖ ការបង្កើតឱ្យមានវប្បធម៌អនុវត្តការងារ ការបង្កើតការងារ និងយន្តការវាយតម្លៃការងារ។ រីឯការគ្រប់គ្រងធនធានសម្ភារ និងថវិកា អ្នកសិក្សានឹងទទួលបានចំណេះដឹងដែលទាក់ទងទៅនឹងក្របខ័ណ្ឌ និងលំនាំនៃការរៀបចំ ការប្រើប្រាស់ និងការពិនិត្យតាមដាន។

### មុខវិជ្ជាទី៣៖ ការគ្រប់គ្រងសាលារៀន (២)៖ ការលើកកម្ពស់ការបង្រៀន និងរៀន (០៦ក្រេឌីត)

មុខវិជ្ជានេះ ផ្តល់នូវគោលគំនិតសំខាន់ៗដែលទាក់ទងទៅនឹងកម្មវិធីសិក្សា ការអភិវឌ្ឍកម្មវិធីសិក្សា និងការអនុវត្តជាក់ស្តែង ក្នុងគោលបំណងដើម្បីបង្កើតឱ្យមានបរិយាកាសនៃការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់នៅតាមសាលារៀន។ គំរូនៃការបង្រៀន និងរៀនតាមបែបទំនើបជាច្រើនពាក់ព័ន្ធទៅនឹងគោលវិធីសិស្សមជ្ឈមណ្ឌល ក៏ត្រូវបានយកមកបង្ហាញផងដែរដូចជា៖ វិធីសាស្ត្របង្រៀន

តាមបែបវិធីវិទ្យាសាស្ត្រ តាមបែបរិះរក (IBL) តាមបែបដោះស្រាយបញ្ហា (Problem Solving)តាមបែបស្ថាបនានិយម (Constructivism) តាមបែបផែនទីគំនិត (Concept Map) តាមបែបE-5 (5Es Method) និងតាមបែបការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (Education for Sustainable Development) ជាដើម។លើសពីនេះទៅទៀត មុខវិជ្ជានេះក៏បានផ្តល់ជូននូវជំនាញជាមូលដ្ឋានដែលទាក់ទងទៅនឹងការគ្រប់គ្រង និងការវាយតម្លៃលើការបំពេញការងាររបស់គ្រូបង្រៀន ព្រមទាំងបង្កើតឱ្យមាននូវបរិស្ថានសាលារៀន និងបន្ទប់រៀនដែលអាចធានាគុណភាពនៃការបង្រៀន និងរៀន មានការរីកចម្រើន។

## មុខវិជ្ជាទី៤៖ ឧត្តមភាពបុគ្គល (០៥ក្រេឌីត)

មុខវិជ្ជានេះ ធ្វើការពណ៌នាជាសំខាន់ទៅលើការបំពេញការងាររបស់នាយកសាលា ដែលគ្របដណ្តប់នូវរាល់គ្រប់ទិដ្ឋភាពនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពខ្ពស់ មានក្រមសីលធម៌វិជ្ជាជីវៈ មានការគិត និងការបង្កើតថ្មីជាលក្ខណៈយុទ្ធសាស្ត្រ និងមានការប្រកួតប្រជែង។ លើសពីនេះទៅទៀត មុខវិជ្ជានេះក៏បានបង្ហាញអំពីគោលគំនិតទាំងឡាយស្តីអំពីការដឹកនាំសាលារៀន និងអាកប្បកិរិយាល្អៗរបស់នាយកសាលាដែលជាកត្តាសំខាន់ៗក្នុងការលើកកម្ពស់គុណភាពរបស់គ្រូបង្រៀន និងបុគ្គលិកផ្សេងៗទៀត ក៏ដូចជាសកម្មភាពនៅក្នុងសាលា។

## មុខវិជ្ជាទី៥៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធ (០៣ក្រេឌីត)

មុខវិជ្ជានេះ ត្រូវបានរៀបចំឡើងយ៉ាងពិសេសដើម្បីបង្កើនសមត្ថភាពជំនាញក្នុងការលើកម្ពស់ការចែករំលែកតួនាទី និងភារកិច្ច សំដៅធ្វើយ៉ាងណាឱ្យសាលាមានការរីកចម្រើន មានបណ្តាញច្បាស់លាស់ មានកិច្ចសហប្រតិបត្តិការល្អ និងមានស្ថិរភាពលើទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ តាមរយៈបណ្តុះដល់អ្នកសិក្សាឱ្យចេះពិភាក្សាគ្នា ចេះបង្កើតនូវសេចក្តីជឿទុកចិត្ត ចេះដឹកនាំសហគមន៍អភិវឌ្ឍន៍សាលារៀន ព្រមទាំងបង្ហាញពីរបៀបផ្តល់អំណាចទៅសហគមន៍ដើម្បីលើកកម្ពស់ និងកែលម្អការបំពេញការងារផ្សេងៗ។ មុខវិជ្ជានេះ ក៏ផ្តល់ដល់អ្នកសិក្សាផងដែរ ពីរបៀបទាក់ទងជាមួយភាគីពាក់ព័ន្ធ និងការគ្រប់គ្រងទំនាស់នានា ជាពិសេសលើជំនាញក្នុងការចរចា។

## មុខវិជ្ជាទី៦៖ អធិការកិច្ចសាលារៀន (០៦ក្រេឌីត)

ការធ្វើអធិការកិច្ចនៅតាមសាលារៀន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការងារ និងការអភិវឌ្ឍសាលារៀន។ មុខវិជ្ជានេះ នឹងផ្តោតសំខាន់ទៅលើបញ្ញត្តិនៃប្រព័ន្ធធានាគុណភាពអប់រំដែល

មានសមាសភាពចំនួន៤គឺ៖ (១) ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ (២) ការបង្រៀន និងរៀន (៣) ការធ្វើឱ្យសម្រេចលទ្ធផលសិក្សារបស់សិស្ស និង(៤) ស្វ័យវាយតម្លៃសាលារៀន។

## មុខវិជ្ជាទី៧៖ ការអភិវឌ្ឍវិជ្ជាជីវៈ (០៩ក្រេឌីត)

មុខវិជ្ជានេះ ផ្តល់ឱ្យអ្នកសិក្សានូវចំណេះដឹងភាសាអង់គ្លេសលើផ្នែកទំនាក់ទំនង តាមរយៈការសរសេរ និយាយ និងស្តាប់ ជាពិសេស (១) ការធ្វើគារវកិច្ច និងការជម្រាបលា (២) ការសម្តែងការថ្លែងអំណរគុណ ការសុំអភ័យទោស ការទទួលស្វាគមន៍ និងការអបអរសាទរ (៣) ការបង្ហាញពីតម្រូវការ និងអារម្មណ៍មនោសញ្ចេតនា (៤) ការប្រើប្រាស់ពាក្យ និងឃ្លាក្នុងការទំនាក់ទំនង (៥) ការណែនាំខ្លួន (៦) ការរៀបចំដើម្បីជួបជុំគ្នា (៧) ការស្នើសុំ និងផ្តល់ព័ត៌មាន (៨) ការជជែកអំពីការអប់រំ និងការចាប់អារម្មណ៍ (៩) ការដាក់ពាក្យស្នើសុំ (១០) ការប្រើប្រាស់ទូរសព្ទ (១១) ការសិក្សាពីបែបបទនៃការសរសេរ និងការសរសេរលិខិតផ្លូវការ ជាដើម ។ល។

មុខវិជ្ជានេះលើកឡើងផងដែរពីសារៈសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការអប់រំទាំងទ្រឹស្តី និងការអនុវត្តរួមមាន៖ (១) Microsoft Word (២) Microsoft Power Point និង(៣) Microsoft Excel។

## មុខវិជ្ជាទី៨៖ វិធីសាស្ត្រនៃការស្រាវជ្រាវក្នុងវិស័យអប់រំ (០៣ក្រេឌីត)

មុខវិជ្ជានេះ នឹងផ្តោតលើមូលដ្ឋានគ្រឹះវិធីសាស្ត្រស្រាវជ្រាវអប់រំ ដែលរួមមានការស្រាវជ្រាវតាមបែបគុណវិស័យ និងបរិមាណវិស័យ ការជ្រើសរើសសំណាកគំរូ ក្រមសីលធម៌ក្នុងការស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ និងការវិភាគលទ្ធផលស្រាវជ្រាវ ក្នុងគោលបំណងបង្កើនសមត្ថភាពអ្នកសិក្សាក្នុងការវិភាគត្រិះរិះពិចារណា និងដើម្បីពង្រឹងយុទ្ធសាស្ត្រឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងការអប់រំ។ ការកំណត់និងការវាយតម្លៃលើបញ្ហាស្រាវជ្រាវ ការប្រើប្រាស់ធនធានបណ្ណាល័យ ការប្រមូលទិន្នន័យ និងការសរសេររបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទ ជាចំណុចសំខាន់ក្នុងមុខវិជ្ជានេះ។ អ្នកសិក្សាអាច៖

- កំណត់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ គុណវិស័យ ភាពស្រដៀងនិងភាពខុសគ្នា និងការលើកភស្តុតាងមួយចំនួនមកប្រើប្រាស់នៅក្នុងទម្រង់នៃការស្រាវជ្រាវនីមួយៗ។
- វិភាគបញ្ហាស្រាវជ្រាវ និងទាញចេញនូវសំណួរស្រាវជ្រាវពាក់ព័ន្ធទៅនឹងការអប់រំសម្រាប់ធ្វើការសង្កេត។
- ប្រើប្រាស់គោលការណ៍ស្រាវជ្រាវដើម្បីបង្កើតការចង្អុលបង្ហាញអំពីសំណួរស្រាវជ្រាវ។
- កំណត់និងជ្រើសរើសទ្រឹស្តី និងបញ្ញត្តិជាមូលដ្ឋានសម្រាប់បញ្ហាស្រាវជ្រាវ។
- រៀបចំគម្រោងសិក្សាស្រាវជ្រាវ។

**ការការពារគម្រោងស្រាវជ្រាវ កម្មសិក្សាប្រតិបត្តិ និងការសរសេរនិក្ខេបបទ (០៦ ក្រេឌីត)**

កម្មសិក្សាប្រតិបត្តិដែលមានតម្លៃសិក្សាចំនួន០៦ក្រេឌីត ត្រូវបានដាក់បញ្ចូលក្នុងគោលបំណងដើម្បី ពង្រឹងសមត្ថភាពជំនាញក្នុងការគ្រប់គ្រងគ្រឹះស្ថានសិក្សាមួយ ឱ្យក្លាយទៅជាគ្រឹះស្ថានប្រកបដោយវិជ្ជាជីវៈខ្ពស់ តាមរយៈការប្រឡូកការងារផ្ទាល់នៅគ្រឹះស្ថានណាមួយ។ បន្ទាប់មក អ្នកសិក្សាទាំងអស់តម្រូវឱ្យធ្វើបទបង្ហាញនិងឡើងការពាររបាយការណ៍កម្មសិក្សាឬនិក្ខេបបទរបស់ពួកគេសម្រាប់ការវាយតម្លៃបំពេញលក្ខខណ្ឌសិក្សា។

## ១៣. ការវាយតម្លៃការបណ្តុះបណ្តាល

ការវាយតម្លៃនៃការបណ្តុះបណ្តាល គឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាអាចទទួលបានពីការបណ្តុះបណ្តាលដោយធៀបទៅនឹងវត្ថុបំណងនៃមេរៀននីមួយៗ។ វិធីសាស្ត្រវាយតម្លៃទាំងនោះ រួមមាន៖

- ការចូលរួមពិភាក្សា
- កិច្ចការផ្ទះ (ការធ្វើកិច្ចការជាក្រុម ជាដៃគូ និងជាបុគ្គល)
- ការធ្វើបទបង្ហាញ
- ការប្រឡងត្រួតពិនិត្យ និងការប្រឡងបញ្ចប់មុខវិជ្ជា
- ការការពារនិក្ខេបបទ
- ការប្រឡងបញ្ចប់ការបណ្តុះបណ្តាល

## ឯកសារយោង


វិទ្យាស្ថានជាតិអប់រំ (២០១៨) *ផែនការយុទ្ធសាស្ត្រវិទ្យាស្ថានជាតិអប់រំ២០១៩-២០២៣* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ (២០១៩) *បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

SEAMEO INNOTECH. (2010). *Teaching Competency Standards in Southeast Asian Countries. Philippines*: Regional Education Project Series.

National Institute of Education international. (2020). *Report on the Review of NIE-C's PRESETT and INSETT Curriculums*. Singapore: National Institute of Education International.